ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៤ លេខ ០២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



# Work Activities

ប្រចាំខែ កុម្ភៈ ឆ្នាំ ២០១១



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | ទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសដោយភ្នាក់ងារជ្រើសរើសឯកជន | ១ |
| ២- | សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងថ្នាំកសិកម្ម និង ជីកសិកម្ម | ៣ |
| ៣- | សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល | ៥ |
| ៤- | សេចក្តីព្រាងអនុក្រឹត្យស្តីពី មគ្គុទ្ទេសក៍ទេសចរណ៍ | ៦ |
| ៥- | សេចក្តីព្រាងអនុក្រឹត្យស្តីពីឃោធិនជាប់កិច្ចសន្យា | ៨ |
| ៦- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ៩ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការបញ្ជូនពលករខ្មែរទៅធ្វើការ នៅបរទេសដោយភ្នាក់ងារជ្រើសរើសឯកជន



កាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុក ឆ្នូរ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសដោយភ្នាក់ងារជ្រើសរើសឯកជន** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

អនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងវេទិការដ្ឋាភិបាល និងឯកជន លើកទី១៥ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសដោយភ្នាក់ងារជ្រើសរើសឯកជន ក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ចល្អ ធ្វើឱ្យពលករទទួលបានសេវាពេញលេញសម្រាប់ទៅធ្វើការនៅបរទេស ដោយទទួលបានគ្រប់សេវាទាំងអស់ ក្នុងដំណាក់កាលទាំង៧ របស់ខួបនៃទេសន្តរប្រវេសន៍ការងារដែលរួមមាន (១)ការជ្រើសរើសដ៏ត្រឹមត្រូវ (២)ការណែនាំតម្រង់ទិស និងការរៀបចំមុនចេញដំណើរដ៏ត្រឹមត្រូវ (៣)ការរៀបចំល្អ និងធ្វើដំណើរបានតាមការកំណត់ (៤)ការទៅដល់ និងការដាក់ឱ្យពលករធ្វើការដ៏ត្រឹមត្រូវ (៥)ការធ្វើការងារដ៏ត្រឹមត្រូវតាមកិច្ចសន្យា (៦)ការរៀបចំ និងការបញ្ចប់ការងារត្រឹមត្រូវតាមការកំណត់ និង(៧)ការវិលត្រឡប់មកប្រទេសវិញ និងការធ្វើសមាហរណកម្ម។ សេចក្តីព្រាងអនុក្រឹត្យនេះ ក៏ជាឧបករណ៍សម្រាប់ការពារគ្រប់បែបយ៉ាងចំពោះពលករ ជាពិសេសការការពារកុំឱ្យធ្លាក់ចូលទៅក្នុងការរើសអើង ការជួញដូរ ការកេងប្រវ័ញ្ច និងការរំលោភបំពាននានា ដោយត្រូវធ្វើឱ្យស្របនឹងទិសដៅ ពង្រឹងអភិបាលកិច្ចល្អ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា(១)។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសដោយភ្នាក់ងារជ្រើសរើសឯកជន។





ចាប់ពីដំណើរការដំបូងមកដល់បច្ចុប្បន្ន ការគ្រប់គ្រងការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមបទប្បញ្ញត្តិ អនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៥ ត្រូវបានកែទម្រង់ជាបន្តបន្ទាប់ សំដៅលើកកម្ពស់ ប្រសិទ្ធភាព អភិបាលកិច្ចល្អ ការផ្តល់សិទ្ធិអំណាចដល់ពលករ និងការការពារពលករ ក៏ដូចជាការធ្វើឱ្យពលករបាន ចូលរួមក្នុងកិច្ចអភិវឌ្ឍជាតិ។ ចាប់ពីចុងឆ្នាំ២០០៦ ដោយចំនួនពលករបានកើនឡើងជាលំដាប់ ក្រសួងបានពង្រឹងអភិបាលកិច្ចមួយជំហានទៀត ដោយតម្រូវឱ្យក្រុមហ៊ុនតម្កល់ប្រាក់គ្រប់ចំនួន ១០០ ០០០ ដុល្លារអាមេរិក។ ពេលអនុវត្ត វិធានការនេះ ចំនួនក្រុមហ៊ុនបានចុះពី៤២ មកនៅត្រឹម១២។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើ សេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលចំណងជើង ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តី ព្រាងនេះកាន់តែល្អ ក៏ប៉ុន្តែនៅជំពូកទី២ មានការស្នើសុំកែ សម្រួលជាច្រើន ដែលអង្គប្រជុំយល់ឃើញថា មានការលំបាកក្នុងការកែសម្រួលនៅពេលនេះ ដូចនេះ អង្គប្រជុំបានសម្រេចបង្កើតក្រុមការងារមួយមាន សមាសភាព ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងសាមីក្រសួង ដើម្បីជួយពិនិត្យ កែសម្រួលខ្លឹមសារបន្តនៃសេចក្តីព្រាងនេះតាមស្មារតីអង្គប្រជុំ មុននឹងយកមកដាក់ប្រជុំជំនាញបច្ចេកនៅពេលក្រោយទៀត។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្តីព្រាងឯកសារនេះ៕

## សេចក្ដីព្រាងច្បាប់ស្ដីពី

# ការគ្រប់គ្រងថ្នាំកសិកម្ម និង ជីកសិកម្ម



កាលពីថ្ងៃទី១៥ ទី១៦ និងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុក ឆូរ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំដើម្បីពិនិត្យពិភាក្សាលើ**សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិកអគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្ដីការគណៈរដ្ឋមន្ត្រី។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្ម និង ជីកសិកម្ម ដែលមានសារៈសំខាន់ និងមានភាពចាំបាច់នៃបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងថ្នាំកសិកម្ម និង សារធាតុគីមីកសិកម្មក្នុងក្របខណ្ឌរួមនៃសុវត្ថិភាពស្បៀង និងដើម្បីធានាសង្គតិភាពជាមួយអនុសញ្ញាអន្តរជាតិនានា ក្នុងក្របខណ្ឌសាកលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មអន្តរជាតិនូវថ្នាំកសិកម្ម និងសារធាតុគីមីកសិកម្មគ្រោះថ្នាក់។ សេចក្ដីព្រាងច្បាប់នេះ បានឆ្លើយតប និងរួមចំណែកគាំទ្រគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម ព្រមទាំងគោលនយោបាយជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករផងដែរ ដែលទាមទារការធានាគុណភាព និងសុវត្ថិភាពនៃកសិផល ដោយមានទំនាក់ទំនងជាចាំបាច់ក្នុងការគ្រប់គ្រងការធ្វើពាណិជ្ជកម្ម និងការប្រើប្រាស់ថ្នាំកសិកម្ម និង ជីកសិកម្ម ដែលជាធាតុចូលសំខាន់ក្នុងផលិតកម្មកសិកម្ម។

ការរៀបចំសេចក្ដីច្បាប់នេះផ្អែកតាម៖

១-រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា៦៨ ចែងថា" រដ្ឋហាមឃាត់ និង ផ្ដន្ទាទោសជាទម្ងន់ដល់ជនណាដែលនាំចូលផលិត លក់ដូរគ្រឿងញៀន ទំនិញក្លែងក្លាយហួសពេលប្រើប្រាស់ ដែលប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើប្រាស់"។

២-គោលនយោបាយវិស័យកសិកម្មជាតិ និង យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដំណាក់កាលទី២ សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា យុទ្ធសាស្ត្រអាទិភាពនៃការអភិវឌ្ឍវិស័យកសិកម្ម ព្រមទាំងគោលនយោបាយជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ។

៣-កម្រងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខណ្ឌនៃការពង្រឹងវិធានការត្រួតពិនិត្យ និង គ្រប់គ្រងសម្ភារៈកសិកម្ម។

៤-លក្ខខណ្ឌពាក់ព័ន្ធក្នុងការចូលជាសមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) របស់ព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខណ្ឌរបាំងបច្ចេកទេសនៃការតម្រូវបមាណីយសម្រាប់ការធ្វើពាណិជ្ជកម្ម និង កិច្ចបញ្ជិកាថ្នាំកសិកម្ម និង ជីកសិកម្ម។

៥-អនុសញ្ញារ៉ូធើដាម (Rotterdam Convention) ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមីគ្រោះថ្នាក់ និង ថ្នាំកសិកម្ម ក្នុងពាណិជ្ជកម្មអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាកំពុងរៀបចំស្នើសុំចូលជាសមាជិកភាគីនៃអនុសញ្ញានេះ។

៦-គោលការណ៍ណែនាំរបស់អង្គការស្បៀង និង កសិកម្មសហប្រជាជាតិ (FAO) ស្តីពីការកសាងច្បាប់ ស្តីពីថ្នាំកសិកម្មក្របខណ្ឌជាតិ(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្តីព្រាងឯកសារនេះនៅផ្នែកទី៤៕





(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និង ជីកសិកម្ម។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

កាលពីថ្ងៃទី១៥ និងថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ ម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អ៊ូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ខៀវ សារ៉េត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល** ដោយមានការអញ្ជើញចូលរួមប្រជុំពីតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃគ.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

របបសន្តិសុខសង្គមនៅកម្ពុជាត្រូវបានបង្កើតឡើងនាសម័យមុនសង្គ្រាម ហើយត្រូវលុបបំបាត់ក្នុងរបបប្រល័យពូជសាសន៍។ ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ ស្ថាប័នរដ្ឋនានាត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ កម្មាភិបាល បុគ្គលិក កម្មកររដ្ឋត្រូវបានជ្រើសរើសឱ្យចូលធ្វើការ និងទទួលរបបឧបត្ថម្ភតាមស្ថានភាពជាក់ស្តែងនៃ ដំណាក់កាលនីមួយៗ ព្រមទាំងទទួលបាននូវរបបសន្តិសុខសង្គម ដែលមានជាអាទិ៍ ការចូលនិវត្តន៍ ការបាត់បង់ សម្បទាវិជ្ជាជីវៈ អ្នកនៅក្នុងបន្ទុក មាតុភាព គ្រោះថ្នាក់ការងារ មរណភាព ករណីមានជំងឺ និងជួបការលំបាកខ្លាំង និងទទួលបាននូវការកែសម្រួលជាបន្តបន្ទាប់ រហូតមកដល់ពេលបច្ចុប្បន្ន សមស្របតាមស្ថានភាពសេដ្ឋកិច្ចនិងវឌ្ឍនភាពរបស់សង្គមជាតិ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី ការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ក្នុងគោលបំណងដូចខាងក្រោម៖

-កំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជស៊ីវិល (ប.ជ.ស.) ដែលជាកាតព្វកិច្ចត្រូវបង់ដោយរាជរដ្ឋាភិបាល និងមន្ត្រីរាជការស៊ីវិលម្នាក់ៗ។

-បង្កើតឱ្យមានប្រភពធនធានផ្ទាល់មួយច្បាស់លាស់ និងគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ ប.ជ.ស. និងសម្រាប់បើកផ្តល់របបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល និងការគ្រប់គ្រងដំណើរការការងាររដ្ឋបាលរបស់ ប.ជ.ស.។

-បង្កើនប្រសិទ្ធភាពបើកផ្តល់របបជូនមុខសញ្ញារបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល។

-អនុវត្តគោលនយោបាយរបបសន្តិសុខសង្គមឱ្យមានប្រសិទ្ធភាព(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# មគ្គុទ្ទេសក៍ទេសចរណ៍

កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC)និង ឯកឧត្តម **ឡាំ ខា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងទេសចរណ៍ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រសួងទេសចរណ៍បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ ក្នុងគោលបំណងពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍមគ្គុទេសក៍ទេសចរណ៍ ឱ្យទទួលបាននូវប្រសិទ្ធភាព គុណភាព និងធានាបានការគោរពអនុវត្តតាមក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទេសក៍ចរណ៍ ផ្តល់ភាពកក់ក្តៅដល់ទេសចរណ៍ និងចូលរួមទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍ ព្រមទាំងធានាដល់ការថែរក្សាធនធានធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទម្លាប់ ស្របតាមឆន្ទៈរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព។

ក្រសួងទេសចរណ៍បានធ្វើការបណ្តុះបណ្តាលមគ្គុទេសក៍ចរណ៍បានចំនួន ៤.៣២៤នាក់ ក្នុងនោះ៖



នៅរាជធានីភ្នំពេញ មានចំនួន ៨៨៧នាក់ និងនៅខេត្តសៀមរាប មានចំនួន ៣.៤៣៧នាក់។

ចំពោះការផ្តល់អាជ្ញាបណ្ណទេសចរណ៍បច្ចុប្បន្ន គិតត្រឹមខែធ្នូ ឆ្នាំ២០១០ មានមគ្គុទេសក៍ទេសចរណ៍អាជីពសរុបចំនួន ៣២២៦នាក់ ក្នុងនោះ នៅរាជធានីភ្នំពេញ មានចំនួន ៣៧១នាក់ និងនៅខេត្តសៀមរាបមានចំនួន ២៨៥៥ នាក់ បែកចេញជា ១១ភាសា ដែលបានឆ្លងកាត់វគ្គបណ្តុះបណ្តាល និងមានអាជ្ញាបណ្ណដែលផ្តល់ដោយក្រសួងទេសចរណ៍។

សភាពការណ៍ពិភពលោកបន្ទាប់ពីវិបត្តិសេដ្ឋកិច្ច សម្រាប់ឆ្នាំ២០១០ មានទេសចរណ៍ប្រមាណ ៩៣៥លាននាក់ គឺមានកំណើនភ្ញៀវទេសចរណ៍អន្តរជាតិប្រមាណ៦.៧% បើធៀប នឹង ឆ្នាំ២០០៩ ក្នុងនោះ៖

-តំបន់អាស៊ី-ប៉ាស៊ីហ្វិក កើនឡើងប្រមាណ ១៣% ក្នុងនោះតំបន់អាស៊ីអាគ្នេយ៍កើនប្រមាណ ១២.៥%

-តំបន់អាមេរិកកើនប្រមាណ ៨%

-តំបន់អឺរ៉ុបកើនប្រមាណ ៣%

-តំបន់អាហ្វ្រិកកើនប្រមាណ ៦%

-តំបន់មជ្ឈិមបូព៌ាកើនប្រមាណ ១៤%



សម្រាប់តំបន់អាស៊ានក្នុងឆ្នាំ២០១០ ទទួលបានទេសចរណ៍ អន្តរជាតិប្រមាណ៦៥នាក់ ក្នុងនោះ កម្ពុជាទទួលបានទេសចរណ៍អន្តរជាតិ ជាង២.៥ លាននាក់ កើនឡើង ១៦% បើធៀបនឹងឆ្នាំ ២០០៩ ដែលមានប្រពភមកពីអាស៊ី-ប៉ាស៊ីហ្វិក ៦៧.៧០% ក្នុងនោះមកពីតំបន់អាស៊ានប្រមាណ ៣៤.១% អឺរ៉ុប ១៦.៥១% អាមេរិក ៧.៩៤%(១) ។





អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានកត់សម្គាល់ឃើញថា សេចក្តីព្រាងនេះមានលក្ខណៈខ្វះខាតចំណុចមួយចំនួន ដូចនេះ អង្គប្រជុំបានសម្រេចបង្កើតក្រុមការងារមួយមាន សមាសភាព ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងសាមីក្រសួង ដើម្បីជួយពិនិត្យកែសម្រួលខ្លឹមសារបន្តនៃសេចក្តីព្រាងនេះតាមស្មារតីអង្គប្រជុំ មុនយកមកដាក់ប្រជុំជំនាញបច្ចេកនៅពេលក្រោយទៀត។

អង្គប្រជុំជំនាញបច្ចេកទេស បានផ្អាកការពិភាក្សាលើសេចក្តីព្រាងឯកសារនេះ៕

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# យោធិនជាប់កិច្ចសន្យា



កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឡុង ឈាង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី **យោធិនជាប់កិច្ចសន្យា** ដោយមាន ការអញ្ជើញចូលរួមពីតំណាងក្រសួងការពារជាតិ សមាជិកអគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

ដោយយោងតាមមាត្រា៤១ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីយោធិនជាប់កិច្ចសន្យា ក្នុងគោលបំណងដូចខាងក្រោម៖

-បង្កើតនិងពង្រឹងមូលដ្ឋានគ្រឹះនៃប្រភពកម្លាំងសម្រាប់កងយោធពលខេមរភូមិន្ទ

-ជ្រើសរើសកម្លាំងជំនាញពីមជ្ឈដ្ឋានពលរដ្ឋទូទៅសម្រាប់ចូលបម្រើការងារសេវារដ្ឋបាល ជំនាញបច្ចេកទេស និងប្រតិបត្តិការសឹក

-កំណត់លក្ខណៈសម្បត្តិ ឋានន្តរសក្តិ ស្ថានភាពបាត់បង់សុខភាព សមត្ថភាពការងារ ការហ្វឹកហ្វឺនវិជ្ជាជីវៈ និងគុណប្រយោជន៍របស់យោធិនជាប់កិច្ចសន្យា។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលខ្លឹមសារ ពាក្យពេចន៍ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្តីព្រាងឯកសារនេះនៅមាត្រា៨៕

---

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និង ជីកសិកម្ម។

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០២/១១<br>ម៉ោង ១៦ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង "ផ្តល់ជំនួយថវិកាចំនួន ១,៣លានដុល្លាអាមេរិក" សម្រាប់គាំទ្រកិច្ចសហប្រតិបត្តិការបោសសំអាតមីន និងកាកសំណល់សង្គ្រាមរបស់កងឯកភាពកំចាត់មីនទី៦ របស់ CMAC នៅក្នុងខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ រយៈពេល ១២ខែ ក្នុងឆ្នាំ ២០១១ រវាងអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ជាមួយរដ្ឋាភិបាលនៃសាធារណៈសហព័ន្ធអាល្លឺម៉ង់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | ០៤/០២/១១<br>ម៉ោង ១៩ : ៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងជាមួយឯកអគ្គរាជទូតប្រទេសជប៉ុន នៅស្ថានទូត។ |
| ៣ | ០៧/០២/១១<br>ព្រឹក-ល្ងាច | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីពិនិត្យលើ៖<br>១-បូកសរុបការងារប្រចាំឆ្នាំ២០១០ និងលើកទិសដៅការងារឆ្នាំ២០១១<br>២-បញ្ហាផ្សេងៗ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៤ | ០៨/០២/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យលើ៖<br>១-សេចក្តីព្រាង គោលនយោបាយជាតិ ស្តីពីការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជា។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកែសម្រួល មាត្រា១៣ មាត្រា១៤ មាត្រា១៥ មាត្រា ១៦ មាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២០ មាត្រា២១ និងមាត្រា២៣ នៃអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៩/០២/១១<br>ម៉ោង ១៤ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបិទសន្និបាតបូកសរុបការងារពាណិជ្ជកម្មឆ្នាំ២០១០ និងលើកទិសដៅការងារពាណិជ្ជកម្មឆ្នាំ២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ នៅសាលសន្និសីទចតុមុខ។ |
| ៦ | ១០/០២/១១<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើក មហោស្រពសិល្បៈមហាជនខ្មែរទូទាំងប្រទេស ឆ្នាំ២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលសន្និសីទចតុមុខ ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ១០/០២/១១ ម៉ោង ១៥:៣០ នាទី | ដឹកនាំកិច្ចប្រជុំ ដើម្បីពិភាក្សាអំពីការកំណត់ប្រភពថវិកាសម្រាប់ធ្វើគ្រឿងបង្គុំជំបូលកញ្ចក់នៃគម្រោងសាងសង់សារមន្ទីរវាយនភ័ណ្ឌប្រពៃណីអាស៊ីនៅបូរីវប្បធម៌ និងទេសចរណ៍-អង្គរ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៨ | ១១/០២/១១ ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១.សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គម។<br>២.សេចក្តីព្រាងអនុក្រឹត្យ ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ។<br>៣.សេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិធានការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្ម ផលិតផលថ្នាំជក់ ។<br>៤.បញ្ហាផ្សេងៗ ។ |
| ៩ | ១៤/០២/១១ ម៉ោង ០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១០ | ១៤/០២/១១ ម៉ោង ១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំសម្រាប់ក្រុមការងារសាងសង់អគារថ្មីនៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១១ | ១៦/០២/១១ ម៉ោង ១៦:៣០នាទី | ចូលរួមជាកិត្តិយសក្នុងសន្និបាតប្រចាំឆ្នាំរបស់ គណៈវិស្វករកម្ពុជាលើកទី១ អាណត្តិទី១ និងពិធីប្រគល់វិញ្ញាបនប័ត្រវិស្វករចុះបញ្ជី និងវិស្វករអាជីព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |
| ១២ | ១៧/០២/១១ ម៉ោង ០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆ្នាំ២០១០ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៣ | ២០/០២/១១ ម៉ោង ១៧:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម BULENT ARINC ឧបនាយករដ្ឋមន្ត្រី នៃប្រទេសទួរគី នៅសណ្ឋាគារណាហ្គាលវើល ។ |
| ១៤ | ២១/០២/១១ ម៉ោង ១៧:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់និងទទួលនិមិត្តរូប នូវអំណោយជាសម្ភារៈការិយាល័យ ពីសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៥ | ២២/០២/១១ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ |
| ១៦ | ២២/០២/១១ ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។<br>ដើម្បីត្រៀមប្រជុំជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |

| លរ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៧ | ២៣/០២/១១<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១០ និងលើកទិសដៅការងារឆ្នាំ២០១១ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ១៨ | ២៣/០២/១១<br>ម៉ោង ១៦:០០នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រនៅទូទាំងប្រទេសកម្ពុជា។<br>២-សេចក្តីព្រាង គោលនយោបាយជាតិ ស្តីពីការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជា។<br>៣-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកែសម្រួល មាត្រា១៣ មាត្រា១៤ មាត្រា១៥ មាត្រា១៦ មាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២០ មាត្រា២១ និងមាត្រា២៣ នៃអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។<br>៤-បញ្ហាផ្សេងៗ ។ |
| ១៩ | ២៤/០២/១១<br>ម៉ោង ០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំបន្តក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆ្នាំ២០១០ នៅទីស្តីការ គណៈរដ្ឋមន្ត្រី ។ |
| ២០ | ២៤/០២/១១<br>ម៉ោង ១៤:៣០នាទី | ចូលរួមស្តាប់បទឧទ្ទេសនាម របស់ឯកឧត្តម **ឆាយ សារុន** អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ស្តីពីការប្រកាសផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើពុករលួយ និងទម្រង់បែបបទនៃការប្រកាសទ្រព្យសម្បត្តិ និងបំណុល នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២១ | ២៥/០២/១១<br>ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១.សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងបុរី ។<br>២.សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់សារធាតុគីមី ដែលទាក់ទងទៅនឹងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ។<br>៣.បញ្ហាផ្សេងៗ÷សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រីដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិលើ "អនុសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការកំណត់ចំណុចប្រសព្វ នៃខ្សែព្រំដែនប្រទេសទាំងបី" ។ |
| ២២ | ២៥/០២/១១<br>ម៉ោង ១៥:៣០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ២៣ | ២៦/០២/១១<br>ម៉ោង ០៩:០០នាទី | ពិនិត្យការដ្ឋានរដ្ឋបាលប្រមូលផ្តុំខេត្តសៀមរាប នៅខេត្តសៀមរាប។ |
| ២៤ | ២៦/០២/១១<br>ម៉ោង ១៤:០០នាទី | ពិនិត្យការដ្ឋានសាងសង់អគារទីស្នាក់ការអាជ្ញាធរអប្សរា នៅខេត្តសៀមរាប ។ |
| ២៥ | ២៧/០២/១១<br>ម៉ោង ០៩:០០នាទី | ពិនិត្យការដ្ឋានសាងសង់សារមន្ទីរវាយនភ័ណ្ឌប្រពៃណីអាស៊ីនៅបូរីវប្បធម៌ និងទេសចរណ៍-អង្គរ នៅខេត្តសៀមរាប ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលសន
## អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០២/១១ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង "ផ្តល់ជំនួយថវិកាចំនួន ១,៧លានដុល្លាអាមេរិក" សម្រាប់គាំទ្រកិច្ចសហប្រតិបត្តិការបោសសំអាតមីន និងកាកសំណល់សង្គ្រាមរបស់កងឯកភាពកំចាត់មីនទី៦ របស់ CMAC នៅក្នុងខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ រយៈពេល ១២ខែ ក្នុងឆ្នាំ ២០១១ រវាងអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ជាមួយរដ្ឋាភិបាលនៃសាធារណៈសហព័ន្ធអាល្លឺម៉ង់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | ០៨/០២/១១ | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យលើ៖<br>១-សេចក្តីព្រាង គោលនយោបាយជាតិ ស្តីពីការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជា។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកែសម្រួល មាត្រា១៣ មាត្រា១៤ មាត្រា១៥ មាត្រា ១៦ មាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២០ មាត្រា២១ និងមាត្រា២៣ នៃអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១០/០២/១១ | ចូលរួមជាកិត្តិយសក្នុងពិធីបើក មហោស្រពសិល្បៈមហាជនខ្មែរទូទាំងប្រទេស ឆ្នាំ២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលសន្និសីទចតុមុខ ។ |
| ៤ | ១៦/០២/១១ | ចូលរួមជាកិត្តិយសក្នុងសន្និបាតប្រចាំឆ្នាំរបស់ គណៈវិស្វករកម្ពុជាលើកទី១ អាណត្តិទី១ និងពិធីប្រគល់វិញ្ញាបនប័ត្រវិស្វករចុះបញ្ជី និងវិស្វករអាជីព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |
| ៥ | ២១/០២/១១ | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់និងទទួលនិមិត្តរូប នូវអំណោយជាសម្ភារៈការិយាល័យ ពីសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៦ | ២៤/០២/១១ | ចូលរួមស្តាប់បទឧទ្ទេសនាម របស់ឯកឧត្តម **ឆាយ សាខុន** អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ស្តីពីការប្រកាសផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើពុករលួយ និងទម្រង់បែបបទនៃការប្រកាសទ្រព្យសម្បត្តិ និងបំណុល នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |

## សកម្មភាពដទៃទៀតរបស់ សមាជិក-សមាជិកា
## នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៧/០២/១១ | ឯកឧត្តម **ម៉ម សារិទ្ធ** ចូលរួមប្រជុំស្តីពី កម្មវិធីបណ្តុះបណ្តាលអំពីការប៉ាន់ស្មានភាពក្រីក្រនៅកម្ពុជា នៅវិទ្យាស្ថានស្ថិតិ នៃក្រសួងផែនការ។ |
| ២ | ១០/០២/១១ | ឯកឧត្តម **ឡុង ឈាង** ចូលរួមប្រជុំពិភាក្សាឆ្លងសេចក្តីព្រាងរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងារប្រចាំខែមករា ឆ្នាំ២០១១ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |
| ៣ | ១៧/០២/១១ | ឯកឧត្តម **ឡុង ឈាង** ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១០ និងទិសដៅឆ្នាំ២០១១ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |

# កិច្ចប្រជុំផ្ទៃក្នុងរបស់ ECOSOCC

កាលពីថ្ងៃទី៣១ ខែមករា និងថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និង ម៉ោង ១៥:០០នាទី នៅក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានរៀបចំកិច្ចប្រជុំដើម្បីបូកសរុបការងារឆ្នាំ២០១០ និងលើកទិសដៅសម្រាប់អនុវត្តការងារឆ្នាំ២០១១ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

ជាលទ្ធផលនៃកិច្ចប្រជុំពីរថ្ងៃនេះ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានសម្រេចនូវខ្លឹមសារលម្អិតនៃរបាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១០ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០១១ ដូចខាងក្រោម៖

I- **សេចក្តីផ្តើម**

**១- ការគ្រប់គ្រង និង ដំណើរការ**

បច្ចុប្បន្ននេះ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) មានថ្នាក់ដឹកនាំ សមាជិក សមាជិកា និងមន្ត្រីគ្រប់ជាន់ថ្នាក់សរុបចំនួន ១៣១រូប ដែលបែកចេញជាសមាជិកអចិន្ត្រៃយ៍ និងសមាជិកមិនអចិន្ត្រៃយ៍ និងមន្ត្រីអគ្គលេខាធិការដ្ឋាន ដែលជាសេនាធិការដូចខាងក្រោម៖



**ក- សមាជិក សមាជិកា** ECOSOCC

| | |
|---|---|
| - ប្រធាន | ០១ |
| - អនុប្រធាន | ០៤ |
| - សមាជិកអចិន្ត្រៃយ៍ | ៥៥ |
| - សមាជិកមិនអចិន្ត្រៃយ៍ | ២៥ |
| - សមាជិកបម្រុង | ០៥ |
| សរុប | ៩០ រូប |

**ខ- អគ្គលេខាធិការដ្ឋានមាន**

| | |
|---|---|
| - អគ្គលេខាធិការ | ០១ |
| - អគ្គលេខាធិការរង | ០៦ |
| - មន្ត្រី | ២៤ |
| - ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រី | ០៤ |
| - មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត | ០៦ |
| សរុប | ៤១ រូប |

ដើម្បីបំពេញភារកិច្ចដែលទីស្តីការគណៈរដ្ឋមន្ត្រី និងរាជរដ្ឋាភិបាលបានប្រគល់ជូន ឲ្យបានជោគជ័យ ECOSOCC បានរៀបចំដំណើរការការងារដោយបែងចែកសមាជិកអចិន្ត្រៃយ៍ជាបីក្រុម គឺក្រុមវិស័យរដ្ឋបាល (**ក្រុមទី១**) ក្រុមវិស័យសេដ្ឋកិច្ច (**ក្រុមទី២**) និងក្រុមវិស័យសង្គមកិច្ច និងវប្បធម៌ (**ក្រុមទី៣**) ទៅតាមក្រសួងស្ថាប័ន និងអនុក្រុមស្រាវជ្រាវសេដ្ឋកិច្ច កសិកម្ម ០១អនុក្រុម អនុក្រុមស្រាវជ្រាវ ស្តីពីលទ្ធភាពបង្កើនថវិកាជាតិ ០១អនុក្រុម ។ ក្រុមនីមួយៗ ដឹកនាំដោយប្រធាន០១រូប ដែលជាអនុប្រធាន ECOSOCC និងអ្នកទទួលខុសត្រូវរបស់ក្រុម០១រូប។

## ២-លទ្ធផលអនុវត្តបាន

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) បានខិតខំប្រឹងប្រែងបំពេញការងារយ៉ាងសកម្មក្នុងការអនុវត្តតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលអាណត្តិទី៤ នៃរដ្ឋសភាទទួលបានជោគជ័យ។" ជាលទ្ធផល ECOSOCC បានពិនិត្យ ពិភាក្សា ផ្តល់យោបល់ និងកែសម្រួលព្រមទាំងវាយតម្លៃផលប៉ះពាល់លើលិខិតបទដ្ឋានគតិយុត្ត វិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការពិភាក្សាតុមូលក្នុងកម្មវិធីវិទ្យុ ទីស្តីការគណៈរដ្ឋមន្ត្រី ដូចខាងក្រោម៖

**តារាងទី១:**

| លទ្ធផល | ក្រុមទី១ | ក្រុមទី២ | ក្រុមទី៣ | សរុប |
|---|---|---|---|---|
| - សេចក្តីព្រាងច្បាប់ | ៤ | ៥ | ២ | ១១ |
| - សេចក្តីព្រាងព្រះរាជក្រឹត្យ | ៥ | 0 | ១ | ៦ |
| - សេចក្តីព្រាងអនុក្រឹត្យ | ១២ | ១១ | ១៣ | ៣៦ |
| - សេចក្តីព្រាងឯកសារ និងគោលនយោបាយផ្សេងៗ | ៦ | ២ | ៤ | ១២ |
| សរុប | **២៧** | **១៨** | **២០** | **៦៥** |
| - ការចេញផ្សាយឯកសារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌៖<br>-ប្រចាំខែ<br>-ប្រចាំឆមាស<br>-ប្រចាំឆ្នាំ | ១២ | | | ១២ |
| - ចេញផ្សាយព្រឹត្តបត្រ ECOSOCC ប្រចាំខែ | ១២ | | | ១២ |
| -ចូលរួមកម្មវិធីវិទ្យុទីស្តីការគណៈរដ្ឋមន្ត្រី<br>១-ស្តីពី ប្រព័ន្ធមរតកមនុស្សរស់<br>២-ស្តីពី ការគ្រប់គ្រងអគារសហកម្មសិទ្ធិ<br>៣- ស្តីពី ច្បាប់ស្តីពីអស្សាមិករណ៍<br>៤- ស្តីពី ស្ថានភាពសេដ្ឋកិច្ចព្រះរាជាណាចក្រកម្ពុជា។ | ៨ដង | | | ៨ដង |

ECOSOCC ក៏បានខិតខំប្រឹងប្រែងធ្វើការស្រាវជ្រាវលើប្រធានបទមួយចំនួនដែលជាបញ្ហាប្រឈម ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល ជាពិសេស ពាក់ព័ន្ធនឹងវិស័យកសិកម្ម បំណុលថវិកាជាតិ ស្ថានភាពដៃគូអភិវឌ្ឍន៍នៅកម្ពុជា ដែលការស្រាវជ្រាវប្រធានបទទាំងនោះមួយចំនួនកំពុងសិក្សា និងមួយចំនួនត្រូវបានបញ្ចប់៖

តារាងទី២:

| ប្រធានបទសិក្សាស្រាវជ្រាវ | កំពុងសិក្សា | បានបញ្ចប់ |
|---|---|---|
| - សិក្សាស្រាវជ្រាវស្ថានភាពដៃគូអភិវឌ្ឍន៍ នៅកម្ពុជា | X | |
| - សិក្សាស្រាវជ្រាវស្តីពី កសិផលសំខាន់ៗផ្សេង ទៀតដូចជា ដំណាំស្រូវ សណ្តែកសៀង ល្ង ដំឡូងមី សណ្តែកបាយ និងស្វាយចន្ទី | | X |
| - សិក្សាស្រាវជ្រាវអំពីស្ថានភាពព្រៃកោងកាង នៅកម្ពុជា | X | |
| - សិក្សាស្រាវជ្រាវ ស្តីពីកៅស៊ូក្នុងនាមទំនិញ សេដ្ឋកិច្ច | | X |
| - សិក្សាស្រាវជ្រាវ ស្តីពីវិស័យជលផល | X | |
| - សិក្សាស្រាវជ្រាវលើប្រធានបទលទ្ធភាព បង្កើនចំណូលថវិកាជាតិ | X | |
| - សិក្សាស្រាវជ្រាវ ស្តីពីបសុព្យាបាល និងផលិតកម្មសត្វនៅព្រះរាជាណាចក្រកម្ពុជា | | X |
| - សិក្សាស្រាវជ្រាវអំពីតម្លៃ អគ្គិសនី និងផលប៉ះពាល់លើការអភិវឌ្ឍន៍សេដ្ឋកិច្ច | X | |

**II- សកម្មភាពការងារ**

ដើម្បីសម្រេចបានលទ្ធផលដ៏ធំធេងដូចមានរៀបរាប់ខាងលើ ECOSOCC បានធ្វើការប្រជុំពិភាក្សាចំនួន ៥៥៩លើក ដូចមានលំអិតដូចខាងក្រោម៖

*តារាងទី២* :

| លទ្ធផល | ក្រុមទី១ | ក្រុមទី២ | ក្រុមទី៣ | សរុប |
|---|---|---|---|---|
| ១-ប្រជុំផ្ទៃក្នុង | ២៧លើក | ៤៨លើក | ១៣លើក | ៨៨លើក |
| ២-ប្រជុំជំនាញបច្ចេកទេស | ៦៧លើក | ៦៦លើក | ៥៣លើក | ១៨៦លើក |
| ៣-ប្រជុំចង្អៀត | ៥លើក | ១៨លើក | ៦៣លើក | ៨៦លើក |
| ៤-ប្រជុំអន្តរក្រសួង | ៥៣លើក | ៤២លើក | ៤០លើក | ១៣៥លើក |
| ៥-ប្រជុំសរុបមុនរាយការណ៍ជូន ឧបនាយករដ្ឋមន្ត្រី | ១៣លើក | ១២លើក | ៧លើក | ៣២លើក |
| ៦-ប្រជុំពិនិត្យចុងក្រោយក្រោមអធិបតី ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីមុនប្រជុំ គណៈរដ្ឋមន្ត្រី | ១៣លើក | ១២លើក | ៧លើក | ៣២លើក |
| សរុបទាំងអស់ ចំនួន | ១៧៨ លើក | ១៩៨ លើក | ១៨៣ លើក | ៥៥៩ លើក |
| - ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ/ប្រចាំឆមាស/ប្រចាំឆ្នាំ | | ១២ | | ១២ |

## ១-ការបណ្តុះបណ្តាលធនធានមនុស្ស

ក្នុងឆ្នាំ ២០១០ ECOSOCC បានបញ្ជូនសមាជិក និងមន្ត្រី ក្នុងអគ្គលេខាធិការដ្ឋានចូលរួមវគ្គ បណ្តុះបណ្តាលធនធានមនុស្សទាំងនៅក្នុងប្រទេស និងទាំងក្រៅប្រទេសដើម្បីលើកកម្ពស់សមត្ថភាព របស់មន្ត្រីក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត។

### ក-ការចូលរួមវគ្គបណ្តុះបណ្តាលនៅក្នុងប្រទេស

បច្ចុប្បន្ននេះ ECOSOCC បានបញ្ជូនមន្ត្រី ០១ រូបឱ្យទៅរៀនក្នុងវគ្គសិក្សាថ្នាក់វិក្រឹតការមន្ត្រីជាន់ខ្ពស់រយៈមួយឆ្នាំនៅសាលាភូមិន្ទរដ្ឋបាល។ ទន្ទឹមនឹងនេះ ECOSOCC ក៏បានបញ្ជូនសមាជិក និងមន្ត្រីមួយចំនួនឱ្យទៅចូលរួមវគ្គសិក្សារយៈពេលខ្លីផ្សេងៗទៀតបានចំនួន ១១វគ្គ ដែលមានអ្នកចូលរួមចំនួន១៣ នាក់ ។

ECOSOCC បានរៀបចំបណ្តុះបណ្តាលមន្ត្រី ស្តីពីការវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋាន គតិយុត្ត ដោយមានអ្នកជំនាញបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បានចំនួន៤លើក។

### ខ-ការចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស

ECOSOCC បានបញ្ជូនសមាជិក និងមន្ត្រីទៅចូលរួមសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ប្រទេស អូស្ត្រាលីក្រោមកម្មវិធី ORIA និងនៅតាមបណ្តាប្រទេសមួយចំនួនទៀតដូចជា ប្រទេស ចិន វៀតណាម ជប៉ុន បារាំង អង់គ្លេស បានចំនួន១១ វគ្គ ក្រោមកម្មវិធី ADB/GMS/PPR កម្មវិធីបណ្តុះបណ្តាលរៀបចំដោយក្រសួងពាណិជ្ជកម្មសាធារណៈរដ្ឋប្រជាមានិតចិន កម្មវិធីបណ្តុះ បណ្តាលគោលនយោបាយសាធារណៈ PPPID ក្រោមគម្រោង ADB ដែលមានអ្នកចូលរួមចំនួន ១៤ នាក់ ។

## ២-ការបង្កើតការិយាល័យវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត (ORIA)

ECOSOCC បានសហការជាមួយ ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីអនុវត្តនូវគម្រោងវាយតម្លៃ ផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត ដែលមានជំនួយបច្ចេកទេសចំនួន ២ ៧២៣ 000 ដុល្លារ ក្នុង នោះ MOU ទី១ ចំនួន ១០៨ 000 ដុល្លារ សម្រាប់ពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០១០ និង MOU ទី២ ចំនួន ២ ៦១៥ 000 ដុល្លារ សម្រាប់ពីខែមេសា ឆ្នាំ២០១១ ដល់ខែ មិថុនា ឆ្នាំ២០១៣ ។

ORIA ត្រូវបានបង្កើតឡើងនៅថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០១០ ដែលមានសមាជិក ១៨រូប និងមានរចនាសម្ព័ន្ធដូចខាងក្រោម៖

| | |
|---|---|
| - នាយកគម្រោង | ១ |
| - នាយករងគម្រោង | ១ |
| - អ្នកគ្រប់គ្រង | ១ |
| - ប្រធានផ្នែក | ៤ |
| - អនុប្រធានផ្នែក | ៤ |
| - មន្ត្រី | ៧ |
| សរុប | ១៨ រូប |

ការបំពាក់សម្ភារៈសម្រាប់ ORIA ដំណាក់កាលទី១ ត្រូវបានបញ្ចប់។ ORIA កំពុងតែសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីរៀបចំ Website របស់ ECOSOCC នឹងប្រព័ន្ធទិន្នន័យទាក់ទង នឹងលិខិតបទដ្ឋានគតិយុត្ត និងបន្តអនុវត្តស្មារតី MOU ទី២ ។ ទីស្តីការគណៈរដ្ឋមន្ត្រីបានប្រគល់បន្ទប់ចំនួន២ (បន្ទប់លេខ៦១០ និង៦១១) ដើម្បីរៀបចំការិយាល័យ ORIA ។

**៣-សកម្មភាពប្រធាន** ECOSOCC

-បានដឹកនាំក្រុមការងារសាងសង់អគារថ្មីនៃទីស្តីការគណៈរដ្ឋមន្ត្រី ទៅទស្សនកិច្ចដកបទពិសោធនៅទីក្រុងគន់មីញប្រទេសចិន ។

-បានចូលរួមអមដំណើរឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងសម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ២១៧លើក ។

-បានចូលរួមសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ចំនួន១៨ លើក ។

ដោយឡែកអនុប្រធាន សមាជិក សមាជិកា និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានបានចូលរួមក្នុងសកម្មភាពផ្សេងៗចំនួន ២៧៦ លើក ។

## III- សន្និដ្ឋាន

សមិទ្ធិផលទាំងឡាយដែល ECOSOCC សម្រេចបានក្នុងឆ្នាំ២០១០ ដែលបានរៀបរាប់ខាងលើ ឆ្លុះបញ្ចាំងឱ្យឃើញជារួមនូវការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ពីសំណាក់ សមាជិក សមាជិកា សមាជិកបម្រុង និងមន្ត្រីអគ្គលេខាធិការដ្ឋាន ជាពិសេស ECOSOCC បានសហការគ្នាយ៉ាងជិតស្និទ្ធ ជាមួយក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការរាជរដ្ឋាភិបាល និងបណ្តាក្រសួង ស្ថាប័ននានា ដើម្បី បំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវដែលទីស្តីការគណៈរដ្ឋមន្ត្រី និងរាជរដ្ឋាភិបាលបាន ប្រគល់ជូន។

## IV- ទិសដៅឆ្នាំ២០១១

ECOSOCC មានទិសដៅ និងផែនការសកម្មភាពរបស់ខ្លួនច្បាស់លាស់ ក្នុងការអនុវត្តការងារ ដើម្បីសម្រេចបានជោគជ័យ ក្នុងនោះ ECOSOCC មានទិសដៅសម្រាប់ឆ្នាំ២០១១ ដូចតទៅ៖

- បន្តខិតខំប្រឹងប្រែងឲ្យអស់ពីកម្លាំងកាយកម្លាំងចិត្តជាធ្លុងមួយដើម្បីអនុវត្តភារកិច្ចផ្សេងៗដែលទីស្តីការគណៈរដ្ឋមន្ត្រី និងរាជរដ្ឋាភិបាលបានប្រគល់ជូនប្រកបដោយប្រសិទ្ធិភាពខ្ពស់
- បន្តខិតខំពង្រឹងនិរន្តរភាពក្នុងការស្រាវជ្រាវលើប្រធានបទផ្សេងៗ ដែលជាបញ្ហាប្រឈមដើម្បីផ្តល់យោបល់ជូនទីស្តីការគណៈរដ្ឋមន្ត្រី និងរាជរដ្ឋាភិបាល
- រៀបចំសំណើសុំតែងតាំង ជូនដល់មន្ត្រីអគ្គលេខាធិការដ្ឋាន ដើម្បីជាការជម្រុញលើកទឹកចិត្ត
- នឹងខិតខំអនុវត្តនូវគម្រោងវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត ដែលកំពុងសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ីឲ្យបានជោគជ័យ ស្របតាមផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្ត RIA ដែលបានដាក់ចេញ ជាពិសេសការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ RIA នៅក្នុងត្រីមាសទី១ នៃឆ្នាំ២០១១ នេះ។





# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | ឯកឧត្តម [illegible] | អនុប្រធាន គ.ស.វ |
| និពន្ធនាយក ៖ | ឯកឧត្តម [illegible] | អគ្គលេខាធិការ គ.ស.វ |
| វិភាគស្ថានភាពសេដ្ឋកិច្ច ៖ | ឯកឧត្តម [illegible] | សមាជិកបម្រុង គ.ស.វ |
| និពន្ធអក្ខរ ៖ | ឯកឧត្តម [illegible] | អគ្គលេខាធិការរង គ.ស.វ |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | លោក [illegible] | ប្រធានការិយាល័យ គ.ស.វ |
| យកព័ត៌មាន និងថតរូប ៖ | លោក [illegible] | ប្រធានការិយាល័យ គ.ស.វ |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | លោក [illegible] | ជំនួយការទេសរដ្ឋមន្ត្រីប្រធាន គ.ស.វ |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in